# ទស្សនៈ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីព្រលឹងខ្មែរ ឬជំនឿខ្មែរ

**web site: hoksavann.org**

ថ្ងៃទី២៧ កក្កដា ២០០៥

ព្រះពុទ្ធសាសនាសំដែងថា មនុស្សជាសត្វពិសេសមានប្រាជ្ញាជាងសត្វតិរច្ឆាន ព្រោះមនុស្សមានសក្តានុភាពទាំងកាយសម្បទានិងចិត្តគំនិត អាចបណ្ដុះបណ្ដាលឲ្យចំរើនលូតលាស់ខាងវប្បធម៌និងសង្គមធម៌ ។ តាមព្រះពុទ្ធសាសនា ការចំរើនលូតលាស់នេះអាស្រ័យហេតុពីរប្រការ គឺអាស្រ័យឧបនិស្ស័យ ដែលបានកសាងល្អពីមុន និងការព្យាយាមត្រូវក្នុងបច្ចុប្បន្ន (បុព្វេ កតបុញ្ញតា, អត្តសម្មាបរណីធិ) ។

មនុស្សជាតិកើតមកជាដំបូង ពុំទាន់ចេះដឹងអ្វីនៅឡើយ ពួកគេរស់នៅជាមួយធម្មជាតិ តាមរអាងភ្នំ ក្រោមម្លប់ព្រៃព្រឹក្សា ចាប់សត្វបានហែកចែកគ្នាស៊ីជាដើម ។ ក្នុងផ្លូវជំនឿ គេជឿថាវត្ថុធម្មជាតិមានចិត្តមានវិញ្ញាណ ដូចជាខ្យល់ព្យុះ រន្ទះបាញ់ ភ្លុំភ្លើងផ្ទុះ ផែនដីញ័រ ពេលដែលបាតុភូតទាំងនេះកើតឡើង ពួកគេមានការភ័យតក់ស្លុត បន់ស្រន់កុំឲ្យធម្មជាតិទាំងនោះកើតឡើង ជំនឿនែននេះហៅថា ជំនឿព្រលឹងនិយម (animism) ។ ពេលក្រោយមក គំនិតមានការវិវត្តន៍ ពួកគេជឿថា វត្ថុធម្មជាតិទាំងនោះគ្មានចិត្តវិញ្ញាណទេ តែវត្ថុធម្មជាតិទាំងនោះមានទេវៈមួយរូបៗថែរក្សា ដែលអាចបណ្ដាលឲ្យប្រព្រឹត្តទៅបែបណាមួយ ស្រេចតែទេវៈនោះបញ្ជាឲ្យកើតឡើង ដូច្នេះហើយបានជាដើម្បីកំចាត់បង់កុំឲ្យគ្រោះមហន្តរាយទាំងនោះកើតឡើង ពួកគេបន់ស្រន់ទេវៈទាំងនោះ ។ ក្រោយមកទៀត មានអ្នកសរសេរបញ្ចេញទស្សនៈថា មានទេវៈដ៏ធំមួយបង្កើតលោកដែលហៅថា ព្រះអាទិទេពបានដល់ព្រះព្រហ្ម ។ និយាយកាត់ឲ្យខ្លី នៅពេលនោះ ព្រះពុទ្ធព្រះបរមគ្រូព្រះសមណៈគោតមបានត្រាស់ដឹងឡើងក្នុងលោក ។ ព្រះអង្គមានព្រះនាមមួយក្នុងពុទ្ធគុណគឺ លោកវិទូ ប្រែថាព្រះអង្គជ្រាបច្បាស់នូវលោក ។ ព្រះអង្គជ្រាបច្បាស់នូចសង្ខារលោក គឺវត្ថុគ្មានវិញ្ញាណទាំងអស់ គ្មានអ្នកណាបង្កើតទេ គឺកើតឡើងឯងតាមច្បាប់ធម្មជាតិ (Natural Law) ។ ព្រះអង្គជ្រាបនូវសត្តលោក គឺរបស់មានវិញ្ញាណទាំងអស់ ដូចមនុស្សសត្វកើតឡើង ស្លាប់កើតទៅតាមអំពើល្អអាក្រក់របស់ខ្លួន ។ ដូច្នេះព្រះពុទ្ធបានត្រាស់ដឹងឡើង បដិសេធព្រះបង្កើតលោក ។ បន្ទាប់មកទៀត មានសាសនាពីរធំទៀតប្រកាសថា ព្រះរបស់គេបង្កើតលោកដែរ ។

ចំពោះជំនឿខ្មែរជំនាន់ដើម ក៏ដូចជាជំនឿមនុស្សដើមដែលទើបកើតទឹកដីដែរ គឺជឿព្រលឹងនិយម បន្ទាប់មកជឿថាមានទេវៈថែរក្សាវត្ថុធម្មជាតិទាំងនោះរហូតជឿខ្មោចបិសាច អារក្សអ្នកតា ចេះឲ្យសុខឲ្យទុក្ខដល់មនុស្ស ។ ទោះបីមានជំនឿក្នុងព្រះពុទ្ធសាសនាស៊ប់ហើយ ដែលប្រៀនប្រដៅឲ្យជឿកម្មផលរបស់ខ្លួនហើយក៏ដោយ ប្រជាពលរដ្ឋខ្មែរនៅមានជំនឿខ្មោចបិសាចអារក្សអ្នកតា កាលពីមួយសតវត្សរ៍មុន នៅតាមសសរកន្ដោងនៃផ្ទះខ្មែរនីមួយ មានធ្វើច្រំមួយអំពីឫស្សីរាងដូចសាជីដាក់សំរាប់ឲ្យខ្មោចស្នាក់នៅ ហៅថាជំនាងផ្ទះ សំរាប់ឲ្យថែរក្សាផ្ទះ ។ នៅតាមផ្ទះមានរបៀបរៀបចំអាសនៈបូជាខ្មោចសំបួជ ហើយមានធ្វើពិធីលៀងអារក្ខតាមផ្ទះខ្លះរៀងរាល់ឆ្នាំ ដើម្បីសុំសេចក្តីសុខសប្បាយ ។ នៅតាមភូមិមានធ្វើកូនខ្ទមតូចមួយហៅថា ផ្ទះព្រះភូមិ ។ នៅតាមស្រុកនីមួយៗ មានធ្វើកូនខ្ទមមួយ ហៅថាខ្ទមអ្នកតាចាស់ស្រុក នៅពេលចៅហ្វាយស្រុកមកកាន់ការថ្មី តែងតែធ្វើពិធីឡើងអ្នកតាចាស់ស្រុក ដើម្បីខ្លួនមកកាន់ការ បានសុខសប្បាយនិងរីកចំរើនក្នុងស្រុក ។ ឯរាបទេវតាមានធ្វើតែផ្ទះខ្មែរខ្លះ ពុំមានធ្វើទូទៅឡើយ ។ នៅពេលមានអាសន្នអន់ក្រ មានវិបត្តិគ្រោះថ្នាក់ មានជម្ងឺដំកាត់ជាដើមបៀតបៀន ជនជាតិខ្មែរតែងតែមានការបន់ស្រន់ខ្មោចបិសាច ខ្មោចដូនខ្មោចតា រហូតបន់ព្រះសំពះទេវតា សូមឲ្យវិបត្តិទាំងនោះបាត់បង់ទៅ ។

លុះមកដល់ចុងសតវត្សទី២០ដើមសតវត្សទី២១ នៅពេលដែលពុទ្ធិកសិក្សាគឺការសិក្សាខាងព្រះពុទ្ធសាសនាបានលូតលាស់ចំរើន យល់កាន់តែច្បាស់នូវធម៌វិន័យរបស់ព្រះពុទ្ធជាម្ចាស់ អំពីហេតុផលនិងកម្មផល ទន្ទឹមគ្នានឹងវិទ្យាសាស្ត្រក៏កាន់តែចំរើនលូតលាស់ ជាពិសេសលូតលាស់ខាងវិជ្ជាពេទ្យផ្នែករោគសាស្ត្រ ជំនឿប្រជាពលរដ្ឋខ្មែរខាងការបន់ស្រន់សុំសេចក្តីសុខពីខ្មោចបិសាចត្រូវចុះខ្សោយកន្លែងខ្លះបាត់ទាំងស្រុងតែម្តង ។ គេឈប់ធ្វើជំនាងផ្ទះ, ខ្ទមព្រះភូមិ ខ្ទមអ្នកតាចាស់ស្រុកជាទូទៅដូចមុនទៀតហើយ ។ ពេលមានវិបត្តិគេតែងដោះស្រាយតាមយថាហេតុស្របតាមន័យរបស់ព្រះពុទ្ធសាសនា ហើយបើជម្ងឺដំកាត់បៀតបៀន គេតែងតែទៅព្យាបាលនៅមន្ទីរពេទ្យ ។

ដោយឥទ្ធិពលព្រះពុទ្ធសាសនាខ្មែរ ជឿបុណ្យជឿបាប ស្គាល់គុណស្គាល់ទោស រស់នៅជាមួយគ្នាក្នុងសង្គមប្រកបដោយសុខដមរមនា ។ ខ្មែរមានចិត្តស្មោះត្រង់នឹងគ្នា កាលពីជំនាន់ដើម នៅពេលខ្ចីប្រាក់កាសឬវត្ថុផ្សេងៗពីអ្នកណាម្នាក់ សន្យាដោយមាត់ទទេ ពុំដែលធ្វើសំបុត្រស្នាមឲ្យអាជ្ញាធរខ្មែរដឹងឮឡើយ ប៉ុន្តែពុំដែលបោកប្រាស់គ្នាឡើយ ដល់ពេលកំណត់តែងតែយកទៅសងគេវិញ ព្រោះមានជំនឿថា បើមិនយកទៅសងគេទេ ជាតិក្រោយនឹងទៅបំរើគេ៥០០ជាតិ ។ ស្រូវបោកបែនហើយទុកចោលក្នុងលាន ពុំដែលមានចោរលួចឡើយ ។ កូនចៅស្រីៗ ទោះបីដើរទៅណា ក៏ពុំឮថាមានបុរសចាប់រំលោភផ្លូវភេទឡើយ ។ល។ សម័យក្រោយមកដោយវប្បធម៌ដទៃជ្រៀតចូល ធ្វើឲ្យឧត្តមគតិល្អដូចពោលមកនេះ ត្រូវរវាតឃ្លាតចេញទៅរកអំពើអាក្រក់វិញខ្លះ ។

តើព្រលឹងខ្មែរ ជំនឿខ្មែរ ទំនោរខ្មែរ ឬមនោសញ្ចេតនាខ្មែរនៅត្រង់ណា ? អ្នកស្រាវជ្រាវខាងប្រវត្តិវិទ្យាបានជ្រាបហើយថា ជនជាតិខ្មែរចាប់ពីបានរស់នៅជាមួយគ្នាជាសង្គម តែងមានមនោសញ្ចេតនាគោរពចាស់ទុំ ជាពិសេសគោរពមេជាងគោរពបា (គោរពម្តាយជាងគោរពឪពុក) ដូចមានពាក្យថា ស្លាប់បាកុំឲ្យស្លាប់មេ។ ប្រុសត្រូវតែទៅដណ្តឹងស្រ្តី មានខាងឪពុកក្មេកខ្លះម្តាយក្មេកខ្លះ តម្រូវឲ្យខាងប្រុសសង់ផ្ទះឲ្យខាងស្រីមួយ តម្រូវឲ្យខាងប្រុសទៅបំរើខាងស្រី២ឆ្នាំសិន ដើម្បីមើលចិត្តគំនិតបុកមារយាទ ។ គំនិតខ្មែរដើមជឿខ្មោចបិសាច អារក្សអ្នកតា ខ្មោចដូនតា អាចផ្តល់សុខផ្តល់ទុក្ខឲ្យដល់ខ្លួន ប៉ុន្តែទស្សនៈខ្មែរពុំជឿព្រះបង្កើតលោកឡើយ ដូច្នេះហើយបានជាពេលដែលសាសនាព្រាហ្មណ៍និងព្រះពុទ្ធសាសនាចូលមកប្រទេសកម្ពុជា ខ្មែរបានសំរេចច្រានចោលសាសនាព្រាហ្មណ៍ ដែលថាព្រះព្រហ្មបង្កើតលោក ហើយបានទទួលព្រះពុទ្ធសាសនាយកមកគោរពប្រតិបត្តិក្នុងជីវភាពប្រចាំថ្ងៃ រហូតមកដល់សព្វថ្ងៃនេះ ដោយព្រះពុទ្ធសាសនាជាញាណទស្សនវិជ្ជាដ៏ខ្ពង់ខ្ពស់ មានសច្ចភាព ជាមាគ៌ាធ្វើឲ្យអ្នកប្រតិបត្តិតាមដល់នូវទីរំលត់ទុក្ខ ។ បន្ទាប់ពីបានទទួលប្រតិបត្តិតាមធម៌របស់ព្រះពុទ្ធមក ជំនឿទៅលើខ្មោចបិសាច ឬវត្ថុស័ក្តិសិទ្ធិខាងក្រៅ ថាឲ្យសុខឲ្យទុក្ខដល់ខ្លួនត្រូវបានលះបង់ ។ ធម៌របស់ព្រះពុទ្ធបានរលាយចូលក្នុងចិត្តគំនិតរបស់ប្រជាពលរដ្ឋខ្មែរ ។ ដូច្នេះគំនិតនិងជំនឿរបស់ប្រជាពលរដ្ឋខ្មែរ មានការវិវត្តន៍ទៅរកការចំរើន គឺជំនឿថាវត្ថុស័ក្តិសិទ្ធិខាងក្រៅមានខ្មោចបិសាចនិងទេវតាជាដើម ថាឲ្យសុខឲ្យទុក្ខ ជាជំនឿមិនសមហេតុផល ផ្លាស់មកជំនឿក្នុងព្រះពុទ្ធសាសនាជាជំនឿប្រកបដោយហេតុផលមានសច្ចភាព។

ត្រង់ចំណុចដែលចិត្តគំនិតនិងជំនឿខ្មែរគ្មានផ្លាស់ប្តូរនេះ គួរពិនិត្យមើលទស្សនៈរបស់លោកកេង-វ៉ាន់សាក់ ដែលវិទ្យុអាស៊ីសេរីយកមកសាកសួរអំពីចិត្តគំនិតនិងជំនឿខ្មែរសម័យបូរាណបំផុតនោះ បំណោះស្រាយខ្លះរបស់គាត់ ជាការប្រឌិតដោយខ្លួនឯងសុទ្ធសាធ ដោយគ្មានឯកសារណាមួយជាភស្តុតាងផងទេ ដំណោះស្រាយខ្លះដោយផ្អែកលើតួអក្សរ ។ កាលពីថ្ងៃមុន លោកឈឹម-សាមេត

វិទ្យុសម្លេងសហរដ្ឋអាមេរិក ក្នុងការធ្វើអត្ថាធិប្បាយរបស់ខ្លួន អំពីចម្លាក់នៅប្រាសាទបន្ទាយស្រី បានបដិសេធទស្សនៈរបស់លោកកេង-វ៉ាន់សាក់ អំពីឈ្មោះចម្លាក់នោះ ដោយរិះគន់ទស្សនៈលោកកេង-វ៉ាន់សាក់ថាចេះតែថា ដោយគ្មានភស្តុតាងពិតឡើយ ។ សូមលើកយកទស្សនៈមួយរបស់លោកកេង-វ៉ាន់សាក់អំពីប្រាសាទអង្គរវត្ត បែរមុខទៅទិសខាងលិច ។ គាត់ថាបានជាអង្គរវត្តបែរមុខទៅទិសខាងលិច ព្រោះប្រជាពលរដ្ឋខ្មែរចង់រំលំស្ដេចឲ្យសញ្ញាដឹងតាមរយៈជាងសំណង់ទាំងនោះ ។ នៅសម័យសង្គមរាស្ត្រនិយម ពុំដែងថាលោកកេង-វ៉ាន់សាក់មានសកម្មភាពបែបណាទេ សម្ដេចនរោត្តម-សីហនុបានចាប់គាត់ដាក់គុក ដោយចោទថាជាបញ្ញវ័ន្តឆ្វេងនិយម (កុម្មុយនិស្ត) ជាមួយនិងបញ្ញវ័ន្តពីររូបទៀត គឺលោកភួង-តុន និងលោកថៅ-សៅ ។ ដូច្នេះការវែកញែកប្រវត្តិសាស្ត្ររបស់លោកកេងវ៉ាន់សាក់ ច្រើនផ្អែកទៅលើគោលគំនិតនយោបាយច្រើនជាងការលើកយកភស្តុតាងពិតប្រាកដតាមលក្ខណៈវិទ្យាសាស្ត្រ ។ កាលសម្ដេចសង្ឃជួន-ណាតបណ្ឌិតអក្សរសាស្ត្រគង់នៅតែងពោលចោទលោកកេង-វ៉ាន់សាក់ថា ជាមេក្រមីអក្សរសាស្ត្រ ព្រោះគាត់ចង់កែប្រែពាក្យខ្មែរខ្លះ ។ ឥឡូវនេះបំណងរបស់គាត់បានសំរេចហើយ ដោយមានពាក្យខ្មែរខ្លះដែលធ្លាប់សរសេរពីមុន ឥឡូវនេះបានត្រូវកែជាច្រើនពាក្យ ជាពិសេសអក្សរ<ឡ>និងអក្សរ<ណ> ស្ទើរតែលុបទាំងស្រុង ហើយអ្នកដែលកែនោះ គឺកូនសិស្សលោកកេង-វ៉ាន់សាក់ពីរនាក់ ដែលជាអាជ្ញាធរក្រសួងអប់រំសម័យរដ្ឋកម្ពុជារបស់បក្សប្រជាជនអំឡុងឆ្នាំ១៩៨០ ។ ពាក្យខ្មែរដែលជនជាតិខ្មែរទូទៅចេះចាំ ព្រមទាំងយល់ន័យរួចហើយ ពុំគួរកែប្រែទេ គួរបង្កើតពាក្យដែលខ្មែរពុំទាន់មាន ឲ្យស្របតាមវិជ្ជដែលកើតឡើងថ្មីៗទៀត ពុំគួរបំផ្លាញរបស់ដែលមានហើយទេ ។ ធម្មតាភាសានៃជនជាតិនីមួយៗ តែងតែខ្ចីពីភាសាដទៃខ្លះ ដើម្បីយកមកបង្គ្រប់ក្នុងភាសាខ្លួនដែលមានកង្វះខាត ដូចភាសាបារាំងនិងអង់គ្លេសមានពាក្យខ្លះខ្ចីពីភាសាក្រិកនិងឡាតាំង ។ យ៉ាងណាមិញ មានពាក្យខ្មែរជាច្រើនបានខ្ចីពីភាសាសំស្ក្រឹតនិងភាសាបាលី ប៉ុន្តែសម្លេងនៃពាក្យទាំងនោះមានសម្លេងជាភាសាខ្មែរសុទ្ធសាធរួចទៅហើយ ។ ដូច្នេះគួរកែត្រឡប់មកពាក្យដូចដើមវិញ ។ អក្សរសាស្ត្រជារបស់សំខាន់ណាស់ មិនត្រូវចេះតែកែប្រែតាមតែចិត្តនឹកឃើញទេ គួរក្រសួងអប់រំនិងរាជបណ្ឌិត្យសភាកម្ពុជាពិចារណាឲ្យបានហ្មត់ចត់ កុំបណ្ដោយឲ្យកែតាមតែទំនើងចិត្ត គួរចេញអនុក្រឹត្យនិងធ្វើអនុសាសន៍បន្ថែមទៀត ដោយត្រូវទុកវចនានុក្រមសម្ដេចជួន-ណាតជាមូលដ្ឋានក្នុងការបង្កើតពាក្យថ្មីៗទៀត ។

អំពីព្រលឹងនិងជំនឿខ្មែរ តាមសំដីលោកកេង-វ៉ាន់សាក់ គាត់ឲ្យតម្លៃតែទៅលើអ្វីដែលជាខ្មែរសុទ្ធ ដូចជាជំនឿខ្មែរទៅលើអារក្សអ្នកតាតាមរបៀបបន់ស្រន់ជាលក្ខណៈមនុស្សជំនាន់ដើម ដែលអារ្យធម៌ពុំទាន់លូតលាស់នៅឡើយនោះ ។ ចំណែកសាសនាព្រាហ្មណ៍និងព្រះពុទ្ធសាសនា គាត់ថានេះជារបស់ឥណ្ឌា ពុំមែនរបស់ខ្មែរទេ ។ ដូចបានពោលមកខាងដើមហើយថា មនុស្សកើតមកពុំមែនចេះឯងទេ គឺចេះមកពីការពិសោធន៍អស់រយៈពេលដ៏យូរ ឆ្លងតាមការសិក្សាពីគ្នាទៅវិញទៅមក ទោះបីមនុស្សមានឧបនិស្ស័យពីជាតិមុនមកខ្លាំងក្លាយ៉ាងណាក៏ដោយ ។ យ៉ាងណាមិញ មនុស្សជំនាន់ដើមពេលកកើតទឹកដី ពុំទាន់ចេះដឹងអ្វីទេ គេរស់នៅរបៀបសត្វតិរច្ឆាន គ្មានផ្ទះសំបែង ចាប់សត្វបរិភោគជាអាហារ ។ មនោសញ្ចេតនារបស់មនុស្សគ្រប់ៗរូប មិនថាមនុស្សសម័យវិទ្យាសាស្ត្រនោះទេ ទោះបីមនុស្សជំនាន់ដើមបំផុត ពេលដែលវិទ្យាសាស្ត្រពុំទាន់លូតលាស់ ក៏មានចិត្តចង់បានសុខចង់បានការលូតលាស់ចំរើនដូចគ្នា តែមធ្យោបាយទៅរកសុខចំរើននោះ មនុស្សជំនាន់ដើមពុំទាន់មានបញ្ញារកឃើញ ដូច្នេះហើយបានជាម្ដងជឿថា វត្ថុធម្មជាតិមានព្រលឹងវិញ្ញាណ ម្ដងបដិសេធហើយជឿថាមានទេវៈនៅគ្រប់គ្រងធម្មជាតិទាំងនោះជាដើម ។ ទាំងអស់នេះជាជំនឿខុស ពុំត្រឹមត្រូវតាមការពិតឡើយ ។ លុះឃើញព្រះពុទ្ធសាសនាជាសាសនាសំដែងធម៌ពិត ជាធម៌នាំមនុស្សឲ្យចាកចេញចាកទុក្ខពិតមែន ជនជាតិខ្មែរក៏លះបង់ជំនឿខុសទាំងនោះ ហើយបែរមកជឿព្រះពុទ្ធសាសនាវិញ ។ ត្រង់ន័យនេះហើយបានជាមានពាក្យក្នុងពុទ្ធសាសនាមួយកន្លែងពោលថា ពហុំ វេសរណំ យន្តិ បព្វតានិ វនានិច អារាមរុក្ខចេត្យានិ មនុស្សា ភយតជ្ជិតា ប្រែថា មនុស្សទាំងឡាយមានចំនួនច្រើន កាលដែលភ័យគ្របសង្កត់ហើយ តែងយកភ្នំទាំងឡាយខ្លះ ព្រៃទាំងឡាយខ្លះ អារាមនិងដើមឈើដែលជាចេតិយទាំងឡាយខ្លះ ជាទីពឹង ។ សេចក្ដីនោះបន្តទៀតថា ទីពឹងនុ៎ះឯងមិនមែនជាទីពឹងដ៏ក្សេមដ៏ឧត្តម បុគ្គលមិនរួចស្រឡះចាកទុក្ខទាំងពួង ព្រោះអាស្រ័យទីពឹងនុ៎ះទេ តែបុគ្គលណាបានដល់នូវព្រះពុទ្ធព្រះធម៌ព្រះសង្ឃជាទីពឹងទីរលឹក ឃើញនូវអរិយសច្ចៈ៤រហូតសំរេចនិព្វាន ទើបជាទីពឹងដ៏ប្រសើរ បុគ្គលរមែងរួចចាកទុក្ខទាំងពួង ព្រោះអាស្រ័យនូវទីពឹងនុ៎ះឯង ។ ដូច្នេះព្រះពុទ្ធរកឃើញសច្ចធម៌សំរាប់រំដោះទុក្ខមនុស្សសត្វទូទៅ ជាពិសេសសំរាប់ជនជាតិខ្មែរ គឺជាព្រះពុទ្ធរបស់ជនជាតិខ្មែរ ។ ប្រៀបដូចអ្នកប្រាជ្ញវិទ្យាសាស្ត្រគ្រប់ផ្នែក ដែលរកឃើញអ្វីមួយ ពុំមែនសំរាប់តែជនជាតិរបស់អ្នករកឃើញនោះទេ គឺសំរាប់មនុស្សលោកទូទៅក្នុងសកលលោក ដែលយកវិជ្ជានេះទៅប្រើប្រាស់ដើម្បីសេចក្ដីសុខចំរើនក្នុងប្រទេសរៀងៗខ្លួន ។ យ៉ាងណាមិញព្រះពុទ្ធត្រាស់ដឹងឡើង ពុំមែនសំរាប់តែជនជាតិណាមួយឡើយ គឺសំរាប់គ្រប់ជនជាតិទាំងអស់ក្នុងលោក ព្រោះសច្ចធម៌ដែលព្រះអង្គត្រាស់ដឹងនេះ ជាសច្ចធម៌ទូទៅត្រូវគ្រប់កន្លែង ត្រូវគ្រប់ពេល ព្រោះជាច្បាប់ធម្មជាតិ ។ ដូចពាក្យថា ហេតុបែបណាផលបែបនោះ ឬអំពើបែបណា ផលបែបនោះ ។ ជនជាតិអាមេរិកដើម ជនជាតិកាណាដាដើម ជនជាតិបារាំងដើម ជាជនជាតិពុំទាន់មានអារ្យធម៌ខ្ពស់នៅឡើយ ឯជនជាតិដែលធ្វើឲ្យប្រទេសទាំងបីនេះលូតលាស់ គឺជនជាតិចំណូលថ្មី ដែលមានអារ្យធម៌និងបញ្ញាខ្ពស់ ។ លោកកេង-វ៉ាន់សាក់បើវែកញែកប្រវត្តិសាស្ត្រខ្មែរដើម្បីការចេះដឹងពុំជាការអ្វីទេ ឲ្យតែវែកញែកនោះត្រឹមត្រូវទៅតាមការពិត ប៉ុន្តែបើវែកញែកដើម្បីបំណងទាញខ្មែរឲ្យវិលត្រឡប់ទៅរកជំនឿណាមួយប្រាសចាកការពិត គ្មានប្រយោជន៍ដល់សង្គមខ្មែរ នោះពុំគួរប្រព្រឹត្តធ្វើទេ ព្រោះបញ្ញាស្មារតីជាតិខ្មែរបានវិវត្តមកដល់កំរិតខ្ពស់ហើយ ។

ព្រលឹងវិញ្ញាណនិងជំនឿខ្មែរ បានស្ថិតនៅជាមួយព្រះពុទ្ធសាសនារាប់ពាន់ឆ្នាំមកហើយ ។ ពិតមែនតែពុទ្ធសាសនាសំដែងអំពីសច្ចធម៌ មានលក្ខណៈជាសកលទូទៅ ប៉ុន្តែខ្មែរយកព្រះពុទ្ធសាសនាមកប្រតិបត្តិ ស្របទៅតាមលក្ខណៈប្រពៃណីនៃជាតិខ្លួន ។ បានសេចក្ដីថា ប្រតិបត្តិតាមធម៌ព្រះពុទ្ធ យកធម៌ព្រះពុទ្ធជាគោល ប៉ុន្តែប្រតិបត្តិទៅតាមលក្ខណៈជាតិខ្មែរ ដែលផ្សេងពីលក្ខណៈថៃ ភូមានិងស្រីលង្កា ។ ដូចជាព្រះពុទ្ធរូបរបៀបខ្មែរ ពិធីកម្មបុណ្យទានរបៀបខ្មែរ ថ្វាយបង្គំព្រះពុទ្ធរបៀបខ្មែរ វិបស្សនារបៀបខ្មែរជាដើម ។ ដោយជនជាតិខ្មែរមានប្រវត្តិសាស្ត្ររបស់ខ្លួនជាងពីរពាន់ឆ្នាំ ហើយធ្លាប់ជាមហាអំណាចនៅសម័យមហានគរផង ជាភស្តុតាងបញ្ជាក់ថា ជនជាតិខ្មែរមានអារ្យធម៌ខ្ពស់ ហើយបានជះឥទ្ធិពលរបស់ខ្លួនមកលើប្រទេសជិតខាងផង ប៉ុន្តែសម័យក្រោយមក រាជាណាចក្រនេះបានត្រូវចុះខ្សោយ ដោយបរទេសឈ្លានពាន ធ្វើឲ្យខ្មែរនិងខ្មែរបែកសាមគ្គីគ្នា ។ ទោះបីព្រឹត្តិការណ៍របស់ប្រទេសប្រែប្រួលយ៉ាងណាក៏ដោយ ព្រះពុទ្ធសាសនាតែងស្ថិតនៅយ៉ាងរឹងមាំក្នុងចិត្តគំនិតខ្មែរ ភស្តុតាងពួកខ្មែរក្រហមបានបំបាត់ព្រះពុទ្ធសាសនាដល់ឫសគល់ ប៉ុន្តែពួកគេពុំអាចបំបាត់ព្រះពុទ្ធសាសនាក្នុងចិត្តគំនិតខ្មែរបានឡើយ ។ ដូច្នេះបញ្ជាក់ថា ព្រះពុទ្ធសាសនាជាព្រលឹង ឬជាអត្តសញ្ញាណរបស់ខ្មែរ ដែលគេពុំអាចញែកចេញឲ្យដាច់ពីគ្នា រវាងព្រះពុទ្ធសាសនានិងជនជាតិខ្មែរបានឡើយ ។ សីលធម៌ធ្លាក់ចុះដោយបញ្ហាសង្គម ដោយវប្បធម៌អាសអាភាសរបស់បរទេសចូលមកជ្រៀតជ្រែកក្នុងចំណោមយុវជន ។ បើគេចាប់អប់រំសីលធម៌ព្រះពុទ្ធសាសនាឲ្យខ្លាំងក្លា នោះសីលធម៌មានកំរិតខ្ពស់និងកើតឡើងវិញ ហើយអំពើហឹង្សានឹងត្រូវថយចុះ ជនជាតិខ្មែរនឹងរស់នៅប្រកបដោយ មេត្តា ករុណា តាមធម៌ព្រះពុទ្ធពុំខានឡើយ ។៚